# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៥៤.... ប្រក.កសក

លិខិតចូល
ថ្ងៃទី១៣.....ខែ.១៣..ឆ្នាំ2010

# ប្រកាស

## ស្តីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើមេមត់ នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍ក្នុងគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្ដានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាមនៃប្រកាសនេះមាន ០៥ សហគមន៍ព្រៃឈើ ចែកចេញជា ០៥ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ១.៧៨៣ (មួយពាន់ប្រាំពីររយប៉ែតសិបបី) ហិកតា ដូចមានក្នុងផែនទីទីតាំងព្រៃសហគមន៍ និងផែនទីសហគមន៍នីមួយៗភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និង ជាប្រព័ន្ធខ្សែព្រំប្រទល់ កំណត់ដោយចំណុចគោល និង និយាមការ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំ និង ការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើ ក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះត្រូវអនុវត្តតាមនីតិវិធី ដូចបានកំណត់នៅក្នុងច្បាប់ស្ដីពីព្រៃឈើ អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ប្រកាសស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

**ប្រការ ៥.-**

ប្រកាស ឬ សេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.–

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋានទីតិកម្មកសិកម្ម ប្រធាននាយដ្ឋានផែនការនិងស្ថិតិ ប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ច័ន្ទ សារុន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពង់ចាម
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ


1:600,000
0
15
30
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960

ឧបសម្ព័ន្ធ ២ : ភ្ជាប់ប្រកាសលេខ [illegible] ចុះថ្ងៃទី ២១ ខែ ៩ ឆ្នាំ ២០១០

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម

| ល.រ | ឈ្មោះសហគមន៍ | ផ្ទៃដី (ហិកតា) | និយាមកា | | | | | | | ចំនួនភូមិ | ឃុំ | ស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | កំណត់បណ្តាញប្រព័ន្ធពីភាគឥណ្ឌា១៩៦០ | | | | | | | | | | |
| ១ | ត្រពាំងព្រីង | ៣៩០ | ជើង | A | 603684 | 1333970 | B | 605536 | 1333362 | ១ | ត្រពាំងព្រីង | តំបែរ | មេមត់ |
| | | | កើត | B | 605536 | 1333362 | C | 603761 | 1332547 | | | | |
| | | | ត្បូង | C | 603761 | 1332547 | D | 602435 | 1333330 | | | | |
| | | | លិច | D | 602435 | 1333330 | A | 603684 | 1333970 | | | | |
| ២ | ចំបក់ | ២១៦ | ជើង | A | 604814 | 1327897 | B | 605929 | 1326360 | ១ | ត្រពាំងព្រីង | តំបែរ | មេមត់ |
| | | | កើត | B | 605929 | 1326360 | C | 604704 | 1325812 | | | | |
| | | | ត្បូង | C | 604704 | 1325812 | D | 603455 | 1327122 | | | | |
| | | | លិច | D | 603455 | 1327122 | A | 604814 | 1327897 | | | | |
| ៣ | ស្រែកក់ | ២៨៧ | ជើង | A | 604863 | 1327021 | B | 605301 | 1325022 | ១ | ត្រពាំងព្រីង | តំបែរ | មេមត់ |
| | | | កើត | B | 605301 | 1325022 | C | 605768 | 1323677 | | | | |
| | | | ត្បូង | C | 605768 | 1323677 | D | 604767 | 1324973 | | | | |
| | | | លិច | D | 604767 | 1324973 | A | 604863 | 1327021 | | | | |
| ៤ | វាលអញ្ចើក | ១៤១ | ជើង | A | 600049 | 1323242 | B | 601067 | 1322813 | ១ | គោកស្រុក | តំបែរ | មេមត់ |
| | | | កើត | B | 601067 | 1322813 | C | 600040 | 1322324 | | | | |
| | | | ត្បូង | C | 600040 | 1322324 | D | 599104 | 1322784 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លិច | D | 599104 | 1322784 | A | 600049 | 1323242 | | | | |
| ៥ | បង្កើរខ្លែង | ៧៤៥ | ជើង | A | 603252 | 1326974 | B | 605996 | 1323549 | ១ | ត្រពាំងក្រឹង | តំបែរ | មេមត់ |
| | | | កើត | B | 605996 | 1323549 | C | 604961 | 1321896 | | | | |
| | | | ត្បូង | C | 604961 | 1321896 | D | 602989 | 1323235 | | | | |
| | | | លិច | D | 602989 | 1323235 | A | 603252 | 1326974 | | | | |
| | | ១៧៨៣ | | | | | | | | ៥ | ២ | ១ | ១ |